គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

NGO Committee on the Rights of the Child

# សៀវភៅមគ្គុទ្ទេសក៍ អង្គការបំពេញការងារ ដើម្បីជួយកុមារ

## ប្រចាំក្រុងព្រះសីហនុ

២០០៧

# បុព្វកថា

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក)ជាសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៤ ហើយបច្ចុប្បន្នមានអង្គការចំនួន៤៦ជាសមាជិក ដោយមានបេសកកម្ម លើកកំពស់ការយល់ដឹងអំពីសិទ្ធិកុមារ ការងារតស៊ូមតិ និងតាមដានការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។

ដើម្បីឱ្យមានភាពងាយស្រួលក្នុងការទំនាក់ទំនង និងការធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាឱ្យកាន់តែ មានភាពរលូននោះ គ.អ.ស.ក រៀបចំបង្កើតឱ្យមានសៀវភៅមគ្គុទ្ទេសក៏នេះឡើង ដែលក្នុងនោះរួមមានព័ត៌មាន ស្តីពីប្រវត្តិអង្គការ ទស្សនៈវិស័យ បេសកកម្ម សកម្មភាពចំបងៗ តំបន់ប្រតិបត្តិការការងារ តារាងរាយនាម បុគ្គលិក និងអាសយដ្ឋានទំនាក់ទំនងរបស់អង្គការសមាជិកនីមួយៗប្រចាំឆ្នាំ២០០៦។

តាងនាមអោយ គ.អ.ស.ក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិកនៃអង្គការបំពេញការងារដើម្បីជួយកុមារក្នុងព្រះសីហនុ និងបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន គ.អ.ស.ក ដែលបានសហការ និងខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្ត។ ឆ្លៀតក្នុងឱកាសនេះដែរ សូមថ្លែងអំណរគុណ និងកត្តញ្ញូតាធមិចំពោះអង្គការន័រវេស្ស៊ីសង្គ្រោះកុមារដែលបានឧបត្ថម្ភជ្រោមជ្រែងទាំងផ្នែកមូលនិធិ និងបច្ចេកទេសក្នុងការផលិតសៀវភៅនេះលេចចេញជារូបរាង។

ជាទីបញ្ចប់ គ.អ.ស.ក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការបំពេញការងារដើម្បីជួយកុមារក្នុងក្រុងព្រះសីហនុ និងបុគ្គលិកទាំងអស់របស់ គ.អ.ស.ក សូមជួបតែសេចក្តីសុខ សំរេចរាល់កិច្ចការនានា និងកាន់តែមានភាពរឹងមាំថែមទៀត ដើម្បីបំរើឱ្យផលប្រយោជន៍ដល់កុមារ។

រាជធានីភ្នំពេញ. ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦

**អគ្គលេខាធិការ**

**ស៊ុំ ចំរុង**

# មាតិកា

**ទំព័រ**


១. អង្គការជួយសង្គ្រោះកុមារកម្ពុជា (CCBO)........................................................................ ១
២. មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR) ........................................................ ៤
៣. អង្គការស្រាវជ្រាវជាតិកម្ពុជា (CNRO).........................................................................៦
៤. អង្គការគ្រួសារថ្មី (Krousar Thmey).......................................................................... ៨
៥. អង្គការជំនួយផ្នែកច្បាប់ នៃកម្ពុជា (LAC)...................................................................... ១០
៦. អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (LICADHO) ..........................................១២
៧. អង្គការម្លប់តាប៉ាង (M’Lop Tapang) ........................................................................... ១៥
៨. អង្គការស្តាហ្វីសកម្ពុជា (Starfish)............................................................................... ១៧

# អង្គការជួយសង្គ្រោះកុមារកម្ពុជា (អជសកក)

CATHOLIC CHILD BUREAU ORGANIZATION (CCBO)

## ១. ប្រវត្តិអង្គការ:

អង្គការជួយសង្គ្រោះកុមារកម្ពុជា(ស៊ីស៊ីប៊ីអូ) ជាអង្គការក្នុងស្រុកដែលធ្វើការជាមូលដ្ឋានយោងទៅលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ស៊ីស៊ីប៊ីអូបានចាប់ផ្តើមធ្វើការងារនេះពីឆ្នាំ២០០០ ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការទប់ស្កាត់ ការជួញដូរ ការរំលោភ និងការកេងប្រវ័ញ្ចនានាលើកុមារនៅក្នុងតំបន់គោលដៅ។ កាលពីដំបូងអង្គការស៊ីស៊ីប៊ីអូ ជាសាខានៃអង្គការអន្តរជាតិមួយដែលមានទីស្នាក់ការនៅទីក្រុងប៉ារីស ប្រទេសបារាំង ដែលអង្គការនេះមាន ការកកើតតាំងតែពី៥០ឆ្នាំ ដែលមានការិយាល័យជាច្រើន ដូចជានៅទ្វីបអាហ្វ្រិក ទ្វីបអាស៊ី ទ្វីបអាមេរិកឡាទីន និងនៅអឺរ៉ុប។ល។ បើតាមបទពិសោធន៍របស់យើង គ្រួសារ គឺជាធនធានដ៏សំខាន់សំរាប់ជួយដល់កុមារ និងថែរក្សាកុមារ ហើយមិនមានស្ថាប័នណាអាចទៅជំនួសបានទេ បើសិនជាគ្រួសារត្រូវបានបំផ្លាញ និងមិនមានលទ្ធភាពដើម្បីធ្វើឱ្យជាសុខភាពដល់កុមារទេនោះ។

## ២. ទស្សនវិស័យ:

យើងធ្វើការនៅក្នុងសហគមន៍ផ្ទាល់ និងដោយមានការចូលរួម ការគ្រប់គ្រងដោយសហគមន៍ជាមូលដ្ឋាន។ ហើយដើម្បីឱ្យការងាររបស់យើងកាន់តែទទួលបានជោគជ័យនៅក្នុងសហគមន៍នោះ យើងត្រូវតែធ្វើការពង្រឹងរចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងសហគមន៍ និងធ្វើការផ្តល់អំណាចទៅឱ្យសហគមន៍ទទួលខុសត្រូវ ដើម្បីជាប្រយោជន៍ដល់កុមារ។

## ៣. បេសកកម្ម:

ចំណុចចាប់ផ្តើមរបស់អង្គការយើងជាទូទៅផ្អែកទៅលើធនធានដែលមាន និងលទ្ធភាពសំរាប់ជួយដល់កុមារដែលមាននៅជុំវិញខ្លួនគេជាសជាងការផ្តោតអារម្មណ៍តែទៅលើបញ្ហាភាពខ្វះចន្លោះ និងការលំបាក។ យើងអាចទទួលបានលទ្ធផលជោគជ័យបើសហគមន៍មានការចូលរួម និងមានការទទួលខុសត្រូវដោយខ្លួនគេផ្ទាល់ ហើយលើសពីនេះទៀត យើងធ្វើការជំរុញលើកទឹកចិត្តដល់កម្មវិធីទាំងឡាយសំរាប់កុមារ និងគ្រួសារកុមារ ដើម្បីឱ្យពួកគេអាចងើបឈរដោយខ្លួនឯងបានបន្ទាប់ពីមានបញ្ហា ឬរងគ្រោះណាមួយ ជាសជាងការផ្តោតតែទៅលើបញ្ហា និងការរំលោភបំពាន។ រាល់កម្មវិធីរបស់អង្គការតែងតែធ្វើតាមរបៀបរ៉ុស៊ីលៀន ហើយលើសពីនោះទៀត ធ្វើឱ្យប្រសើរឡើងនូវសីលធម៌ក្នុងការរស់នៅ និងដោយការសហការណ៍ជាមួយអង្គការដែលមានស្រាប់ ដូចជាអង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលនានា។

## ៤. កម្មវិធី ឬសកម្មភាពចំបងៗ:

### ១. ការអប់រំ

- បង្រៀនអក្ខរកម្ម
- ថ្នាក់ភាសាអង់គ្លេស
- ការបញ្ជូនកុមារឱ្យទៅរៀននៅសាលារដ្ឋ
- ការផ្តល់សម្ភារៈសិក្សាដល់កុមារក្រីក្រឱ្យទៅរៀននៅសាលារដ្ឋ

### ២. ការផ្សព្វផ្សាយ

- អប់រំផ្សព្វផ្សាយអំពីសិទ្ធិកុមារ និងអនុសញ្ញានានាពាក់ព័ន្ធទៅនឹងកុមារ
- ការអប់រំផ្សព្វផ្សាយស្តីពីសិទ្ធិមនុស្ស
- ការអប់រំផ្សព្វផ្សាយអំពីពលកម្មកុមារ

- ការអប់រំផ្សព្វផ្សាយអំពីការជួញដូរ ការរំលោភផ្លូវភេទលើកុមារ និងការបំពាននានាលើកុមារ

**៣. ការបង្កើតបណ្តាញការពារកុមារ**

- មានបណ្តាញសុវត្ថិភាពកុមារ២នាក់នៅតាមភូមិគោលដៅនិមួយៗដែលម្នាក់ជាប្រធានភូមិ ឬអនុប្រធានភូមិ និងម្នាក់ទៀតជាសមាជិកសហគមន៍ដែលមានប្រជាប្រិយ។
- មានក្រុមអ្នកស្ម័គ្រចិត្តជាមនុស្សចាស់១០នាក់ និងក្រុមមិត្តអប់រំមិត្តជាកុមារ១០នាក់នៅតាមភូមិគោលដៅ។
- យើងក៏ជាសមាជិកគណៈកម្មការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ដែលមានសមាជិក៨៦អង្គការ និងក៏ជាសមាជិករបស់បណ្តាញអង្គការតស៊ូមតិនៅក្រុងព្រះសីហនុ មានសមាជិក១៥អង្គការ។

**៤. ការជួយសង្គ្រោះ និងការអន្តរាគមន៍**

- ដោយសហការណ៍ជាមួយអង្គការនានា នគរបាល និងអាជ្ញាធរនានា
- ផ្តល់ការឧបត្ថម្ភចាំបាច់នានាដល់កុមារ
- ធ្វើការបញ្ជូនកុមារឱ្យទៅក្នុងសហគមន៍វិញ បន្ទាប់ពីស្តានីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈរួច។
- ផ្តល់ការព្យាបាលថែទាំនានាដល់កុមារមួយចំនួនដោយសហការណ៍ជាមួយអង្គការនានា និងមន្ទីរពេទ្យ។

**៥. ឥណទាន (ទុនបង្វិល)**

- ផ្តល់ឥណទានខ្នាតតូចដល់គ្រួសារក្រីក្រ ជាពិសេសគ្រួសារកុមាររងគ្រោះដោយយកការប្រាក់ទាប ដែលមានរយៈពេលពី៥ទៅ៦ខែ ដើម្បីយកទៅប្រកបមុខរបរដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ។

**៦. ការបណ្តុះបណ្តាលវិជ្ជាជីវៈ**

យើងធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារក្រុមគោលដៅដែលមានអាយុពី១៥_១៧ឆ្នាំ តាមបែបជាកូនជាងពីរយៈពេល៦ខែទៅដល់២ឆ្នាំ ទៅតាមមុខជំនាញផ្សេងៗគ្នា។

## ៥. តំបន់ការងារ និងប្រភេទកម្មវិធី ឬសកម្មភាពដែលត្រូវអនុវត្ត:

| កម្មវិធី ឬសកម្មភាពការងារ | ផ្នែក | ក្រុមគោលដៅ | តំបន់គោលដៅ | | ប្រភពថវិកា | សហការជាមួយ |
|---|---|---|---|---|---|---|
| | | | ខេត្ត_ក្រុង | ស្រុក_ខ័ណ្ឌ | | |
| ១. ការអប់រំ | ការជួញដូរ និងរំលោភបំពានផ្សេងៗលើកុមារ | កុមារ និងគ្រួសារកុមារដែលងាយរងគ្រោះ | _ក្រុងព្រះសីហនុ | _មិត្តភាព<br>_ព្រៃនប់<br>_ស្ទឹងហាវ | BICE, Misereor, ILO/IPEC, UNESCO, World Vision | មន្ទីរអប់រំ និងមន្ទីរសង្គមកិច្ចក្រុងព្រះសីហនុ |
| ២. ការផ្សព្វផ្សាយ | | | | | | |
| ៣. ការបង្កើតបណ្តាញការពារកុមារ | | | | | | |
| ៤. ការជួយសង្គ្រោះ និងអន្តរាគមន៍ | | | | | | មន្ទីរអប់រំ និងមន្ទីរសង្គមកិច្ចក្រុងព្រះសីហនុ និងនគរបាល |
| ៥. ឥណទាន និងទុនបង្វិល | ឥណទាន | គ្រួសារ និងកុមារធ្វើការងារ | | | | មន្ទីរអភិវឌ្ឍន៍ជនបទ |
| ៦. ការបណ្តុះបណ្តាលវិជ្ជាជីវៈ | បណ្តុះបណ្តាល | គ្រួសារ និងកុមារធ្វើការងារ | | | | មន្ទីរអប់រំ និងមន្ទីរសង្គមកិច្ចក្រុងព្រះសីហនុ |

## ៦. បុគ្គលិកបំរើការខារចំនួន៩នាក់ ប្រុសចំនួន៦នាក់ ស្រីចំនួន៣នាក់

| ល.រ | នាមត្រកូល និងនាមខ្លួន | តួនាទី | លេខទូរស័ព្ទ | ខេត្ត-ក្រុង |
|---|---|---|---|---|
| ១ | លោក ប៉ាវ វណ្ណៈ | ប្រធាន | ០១២ ៨៦៣ ៥២៣ | ក្រុងព្រះសីហនុ |
| ២ | លោក ស្មាន់ អ៊ីប្រាហ៊ីម | អនុប្រធាន | ០១២ ៧៧៤ ៧៧៥ | ក្រុងព្រះសីហនុ |
| ៣ | លោក វ៉ូ សារិន | តំណាងពីមន្ទីរសង្គមកិច្ចក្រុង | ០១៦ ៣៤១ ៨៤១ | ក្រុងព្រះសីហនុ |
| ៤ | លោក សាយ ណាត | មន្ត្រីផ្នែកឥណទាន/គ្រួតពិនិត្យសហគមន៍ | ០១២ ៣៨០ ៩២៧ | ក្រុងព្រះសីហនុ |
| ៥ | លោក ព្រហ្ម ចាន់វិចិត្រ | ជំនួយការគំរោង | ០១១ ៧១៧ ០៧៨ | ក្រុងព្រះសីហនុ |
| ៦ | កញ្ញា ទូច វិសាល | គណនេយ្យ និងរដ្ឋបាល | ០១២ ៥៩៧ ៧៨៧ | ក្រុងព្រះសីហនុ |
| ៧ | កញ្ញា ធាម សុផានី | ភ្នាក់ងារឥណទាន /គ្រួតពិនិត្យសហគមន៍ | ០១៦ ៣៣១ ៤១៥ | ក្រុងព្រះសីហនុ |
| ៨ | កញ្ញា ស៊ា សុផាត | អ្នកបណ្តុះបណ្តាលសហគមន៍ | ០១២ ៧៦៩ ៩៦៦ | ក្រុងព្រះសីហនុ |
| ៩ | លោក ប្រាជ្ញ សក្តិ | អ្នកបណ្តុះបណ្តាលសហគមន៍ | ០៩២ ២៩២ ៣០០ | ក្រុងព្រះសីហនុ |

## ៧. អាសយដ្ឋានទំនាក់ទំនង:

- ឈ្មោះអ្នកទំនាក់ទំនង: លោក **ប៉ាវ វណ្ណៈ** តួនាទី **ប្រធានអង្គការ**
- ផ្ទះលេខ៧២ ផ្លូវឯករាជ្យ សង្កាត់លេខ៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ
- ទូរស័ព្ទលេខ: (៨៥៥) ៣៤ ៩៣៣ ៩៨៣ ទូរស័ព្ទចល័តលេខ: (៨៥៥) ១២ ៨៦៣ ៥២៣
- ប្រអប់សំបុត្រប៉ុស្តិ៍លេខ: NA ប្រអប់សំបុត្រស៊ីស៊ីស៊ីលេខ: NA
- E-mail: bicecam@camintel.com, 012863523@mobitel.com.kh, pavvannak@yahoo.com

# មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (មកកសក)

# CAMBODIAN CENTER FOR THE PROTECTION OF CHILDREN RIGHTS (CCPCR)

## ១. ប្រវត្តិអង្គការ:

មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ ហៅកាត់ថា **មកកសក** ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មិនបំរើគណៈបក្សនយោបាយ មិនប្រកាន់ពូជសាសន៍ ឬសាសនា និងមិនយកផលចំណេញ។ **មកកសក** បានបង្កើតឡើងនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដោយលោក**យឹម ប៉ូ** និងធ្វើសកម្មភាពពេញលេញរបស់ខ្លួននៅខែមិនា ឆ្នាំ១៩៩៥ ដោយគ្របដណ្តប់លើខេត្តមួយចំនួនដូចជា ភ្នំពេញ កំពង់សោម កំពង់ស្ពឺ បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម ស្វាយរៀង តាកែវ កោះកុង ដោយមានការទទួលស្គាល់ពីក្រសួងមហាផ្ទៃចុះថ្ងៃទី២៧_០២_១៩៩៧ និងក្រោមជំនួយឧបត្ថម្ភថវិកា និងបច្ចេកទេសពីម្ចាស់ជំនួយមួយចំនួន។

## ២. ទស្សនវិស័យ:

មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ មានគោលបំណងលើកស្ទួយសិទ្ធិកុមារស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ដោយការពារកុមារឱ្យរួចផុតពីអំពើរំលោភគ្រប់ប្រភេទ និងបង្ការទប់ស្កាត់នូវរាល់អំពើទាំងឡាយណាផ្ទុយនឹងសិទ្ធិកុមារ ដែលមានអាយុតិចជាង១៨ឆ្នាំ ជាពិសេសគឺការចាប់ពង្រត់ក្នុងគោលបំណងជួញដូរ រំលោភ កេងប្រវ័ញ្ចផ្លូវភេទកុមារ និងជួយសង្គ្រោះកុមារឱ្យរួចផុតពីអំពើកេងប្រវ័ញ្ច និងផ្តល់ការថែទាំ ស្តារនីតិសម្បទា ដើម្បីផ្តល់នូវមុខវិជ្ជាជីវៈ និងធ្វើសមាហរណកម្មកុមារទៅរស់នៅជាមួយគ្រួសារក្នុងសង្គមជាតិវិញ។

## ៣. បេសកកម្ម:

១. បំផុសឱ្យមានការយល់ដឹង និងការចូលរួមអនុវត្តសិទ្ធិកុមារ ការពារ និងសង្គ្រោះកុមារងាយរងគ្រោះ និងរងគ្រោះគ្រប់ប្រភេទតាមរយៈកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរគ្រប់ជាន់ថ្នាក់។

២. កុមាររងគ្រោះ និងងាយរងគ្រោះទទួលបាននូវជំរកសមរម្យ ជំនាញវិជ្ជាជីវៈ ការអប់រំផ្លូវកាយ ផ្លូវចិត្ត តាមរយៈការផ្តល់សេវាថែទាំចំលាស់ក្នុងមណ្ឌល និងតាមសហគមន៍ និងធ្វើសមាហរណកម្មទៅក្រុមគ្រួសារ_សហគមន៍វិញ។

## ៤. កម្មវិធី ឬសកម្មភាពចំបងៗ:

១. កម្មវិធីបណ្តាញការពារមូលដ្ឋាន

២. កម្មវិធីមណ្ឌលកសាងសមត្ថភាព និងក្តីសង្ឃឹម និងសមាហរណកម្ម

## ៥. តំបន់ការងារ និងប្រភេទកម្មវិធី ឬសកម្មភាពដែលត្រូវអនុវត្ត:

| កម្មវិធី ឬសកម្មភាពការងារ | ផ្នែក | ក្រុមគោលដៅ | តំបន់គោលដៅ | | ប្រភពថវិកា | សហការជាមួយ |
|---|---|---|---|---|---|---|
| | | | ខេត្ត_ក្រុង | ស្រុក_ខ័ណ្ឌ | | |
| កម្មវិធីអប់រំផ្សព្វផ្សាយ | ផ្សព្វផ្សាយ | កុមារ មនុស្សចាស់ គ្រូបង្រៀន ប៉ូលិស ពេទ្យ និងអាជ្ញាធរមូលដ្ឋាននៅក្នុងសហគមន៍ | _ក្រុងព្រះសីហនុ | _ព្រៃនប់ | -SKN and British Embassy | -ILocal Authorities<br>-Municipal social Affairs<br>-Action Committee<br>-LICADHO |

| | | | | | | |
|---|---|---|---|---|---|---|
| កម្មវិធីមណ្ឌលស្តានិតិសម្បទា | មណ្ឌល | កុមាររងាយរងគ្រោះ កុមារដែលត្រូវគេកេង ប្រវ័ញ្ចផ្លូវភេទ និងកំលាំងពលកម្ម | - ក្រុងព្រះសីហនុ | - គ្រប់ខ័ណ្ឌ | -SKN and British Embassy | -ILocal Authorities<br>-Municipal social Affairs<br>-Action Committee<br>-LICADHO |

## ៦. បុគ្គលិកបំរើការខារចំនួន៨នាក់ ប្រុសចំនួន៥នាក់ ស្រីចំនួន៣នាក់

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | តួនាទី | លេខទូរស័ព្ទ | ខេត្ត-ក្រុង |
|---|---|---|---|---|---|
| ១ | យី ច័ន្ទតារា | ប | អ្នកសំរបសំរួលគំរោង | ០១២ ៨៣០ ២៩៥ | ក្រុងព្រះសីហនុ |
| ២ | ស៊ុត វ៉ាន់ហន | ប | ប្រធានមណ្ឌល | ០១៦ ៧៩១ ៧៥៣ | ក្រុងព្រះសីហនុ |
| ៣ | សាន់ សិលា | ប | គ្រូផ្សព្វផ្សាយ | ០១១ ៦៧៦ ៦២៤ | ក្រុងព្រះសីហនុ |
| ៤ | សំ សុផូន | ប | គ្រូផ្សព្វផ្សាយ | | ក្រុងព្រះសីហនុ |
| ៥ | លុយ ច័ន្ទម៉ារីណា | ស | អ្នកប្រឹក្សាយោបល់ | | ក្រុងព្រះសីហនុ |
| ៦ | ម៉ុំ សំអាន | ស | កាត់ដេរ | | ក្រុងព្រះសីហនុ |
| ៧ | ធី សុខា | ស | អ្នកថែរទាំក្មេង | | ក្រុងព្រះសីហនុ |
| ៨ | ប៉ូ តារារិទ្ធ | ប | សន្តិសុខ | | ក្រុងព្រះសីហនុ |

## ៧. អាសយដ្ឋានទំនាក់ទំនងៈ

- ឈ្មោះអ្នកទំនាក់ទំនងៈ លោក **យី ច័ន្ទតារា** តួនាទី **អ្នកសំរបសំរួលគំរោង**
- ក្រុម១៧ មណ្ឌល ២ សង្កាត់ ៣ ខណ្ឌ មិត្តភាព ក្រុងព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា
- ទូរស័ព្ទលេខៈ (៨៥៥) ១២ ៨៣០ ២៩៥
- Email: ccpcr@forum.org.kh.,chandarayi@yahoo.com
- Web site: NA

# អង្គការស្រាវជ្រាវជាតិកម្ពុជា (ស៊ីអិនរ៉ូ)
# THE CAMBODIAN NATIONAL RESEARCH ORGANIZATION (CNRO)

## ១. ប្រវត្តិអង្គការៈ

CNRO បានបង្កើតនៅថ្ងៃទី ១០ ខែមករា ឆ្នាំ២០០១នៅភ្នំពេញ ចុះបញ្ជីលិខិតលេខ ២១៧ សជណចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០១និងបានបង្កើតនៅក្រុងព្រះសីហនុឆ្នាំ២០០២។ កើតឡើងដោយសារក្រុមអ្នកច្បាប់ដែលក្រុមអ្នកច្បាប់នោះត្រូវបានរងគ្រោះដោយមន្ត្រីមានអំណាចពុករលួយតែងតែរំលោភច្បាប់ជាធរមាន។ មន្ត្រីអង្គការCNRO ប្តេជ្ញាចិត្តពង្រឹងការអនុវត្តន៍ច្បាប់ លើកដំកើងការពារសិទ្ធិមនុស្ស និងការពារលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។

## ២. ទស្សនវិស័យៈ

មានយុត្តិធម៌ មាន សន្តិភាព

## ៣. គោលបំណងៈ

ពង្រឹងវិស័យច្បាប់ឱ្យបានរឹងមាំដើម្បីលើកតំកើងនិងការពារសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ

## ៤. កម្មវិធី ឬសកម្មភាពចំបងៗៈ

១. ទទួលបណ្តឹងពីប្រជាជនក្រីក្រងាយរងគ្រោះ
២. ស៊ើបអង្កេត អន្តរាគមន៍ និង ពិនិត្យឃ្លាំមើលករណីរំលោភសិទ្ធិមនុស្ស
៣. ចូលរួម និង តស៊ូមតិ ជាមួយរដ្ឋាភិបាលដើម្បីឱ្យមានការគោរពក្បួនច្បាប់ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ
- រៀបចំសន្និសិទ្ធការសែត និងសិក្ខាសាលា
- ទាមទារឱ្យមានច្បាប់ថ្មីដើម្បីប្រើប្រាស់ក្នុងប្រទេសកម្ពុជា

៤. ផ្តល់សេវាកម្មផ្នែកច្បាប់ដល់ជនរងគ្រោះករណីរំលោភសិទ្ធិដោយមិនគិតកំរៃ
៥. ផ្សព្វផ្សាយច្បាប់ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ

## ៥. តំបន់ការងារ និងប្រភេទកម្មវិធី ឬសកម្មភាពដែលត្រូវអនុវត្តៈ

| កម្មវិធី ឬសកម្មភាពការងារ | ផ្នែក | ក្រុមគោលដៅ | តំបន់គោលដៅ | | ប្រភពថវិកា | សហការជាមួយ |
|---|---|---|---|---|---|---|
| | | | ខេត្ត-ក្រុង | ស្រុក-ខ័ណ្ឌ | | |
| ១. ទទួលពាក្យបណ្តឹង | ច្បាប់ | ប្រជាពលរដ្ឋងាយរងគ្រោះ | -ក្រុងព្រះសីហនុ | -មិត្តភាព<br>-ព្រៃនប់<br>-ស្ទឹងហាវ | | -អាជ្ញាធរ<br>-LICADHO<br>-ADHOC<br>-LAC |
| ២. ស៊ើបអង្កេត អន្តរាគមន៍ និងពិនិត្យឃ្លាំមើលករណីរំលោភសិទ្ធិមនុស្ស | សិទ្ធិមនុស្ស | | | | | |
| ៣. ចូលរួម និងតស៊ូមតិ | ច្បាប់ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ | រដ្ឋាភិបាល | | | | |
| ៤. ផ្តល់សេវាកម្មផ្នែកច្បាប់ដោយមិនយកកំរៃ | ច្បាប់ | ប្រជាពលរដ្ឋងាយរងគ្រោះ | | | | |
| ៥. ផ្សព្វផ្សាយ | ច្បាប់ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ | | | | | |

## ៦. បុគ្គលិកបំរើការខារចំនួន១នាក់ ប្រុសចំនួន១នាក់

| ល.រ | នាមត្រកូល និងនាមខ្លួន | តួនាទី | លេខទូរស័ព្ទ | ខេត្ត-ក្រុង |
|---|---|---|---|---|
| ១ | លោក សុខ សុខុម | ប្រធាន | ០១២ ៨២៤ ១៤៦ | ក្រុងព្រះសីហនុ |

## ៧. អាសយដ្ឋានទំនាក់ទំនង:

- ឈ្មោះអ្នកទំនាក់ទំនង: លោក **សុខ សុខុម** តួនាទី **ប្រធានអង្គការ**
- ក្រុម ៥ មណ្ឌល ៣ សង្កាត់លេខ២ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ
- ទូរស័ព្ទលេខ: (៨៥៥) ១២ ៨២៤ ១៤៦
- ប្រអប់សំបុត្រប៉ុស្តិ៍លេខ: N399 ប្រអប់សំបុត្រស៊ីស៊ីស៊ីលេខ: NA
- E-mail:.cnro_soksokhom@yahoo.com
- Web site: NA

# អង្គការគ្រួសារថ្មី

KROUSAR THMEY

## ១. ប្រវត្តិអង្គការ:

គ្រួសារថ្មីត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩១ ក្នុងជំរំសាយធូ។ អង្គការនេះបានកកើតឡើងពីភាពជាដៃគូរវាងជនជាតិកម្ពុជា និងលោក **ប៊ីណរ៍ឌុយសាត្លូអាមាំងហ្សេន** ជនជាតិបារាំង ដែលមានបំណងជួយកុមារក្រីក្រ។ ចាប់តាំងពីធ្វើមាតុភូមិនិវត្តន៍ក្នុងឆ្នាំ១៩៩២មក អង្គការគ្រួសារថ្មី បាន និងកំពុងបន្តការគាំពារកុមារទាំងឡាយដែលខ្លួនបានជួយសង្គ្រោះ ក៏ដូចជាបន្តជួយដល់កុមារផ្សេងទៀតដែលស្ថិតក្នុងស្ថានភាពពិបាក នៅក្នុងភូមិ ស្រុក និងខេត្តផ្សេងៗទៀត ដោយសហការយ៉ាងជិតស្និទ្ធជាមួយអ្នកតំណាងនៅប្រទេសបារាំង អ្នកតំណាងនៅប្រទេសស្វីស ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិផ្សេងទៀត។

## ២. ទស្សនវិស័យ:

ធ្វើឱ្យសង្គមមានលក្ខណៈល្អប្រសើរឡើង ដោយផ្តល់ការសិក្សាដល់កុមារ ដើម្បីក្លាយជាមនុស្សធំពេញវ័យប្រកបដោយឯករាជ្យ ម្ចាស់ការ និងស្មារតីទទួលខុសត្រូវខ្ពស់។

## ៣. បេសកកម្ម:

- ជួយកុមារក្រីក្រដែលស្ថិតក្នុងស្ថានភាពពិបាកឱ្យមានជីវិតប្រសើរឡើង ដោយផ្តល់ការអប់រំតាមរយៈ មណ្ឌលគាំពារ មណ្ឌលសង្គ្រោះកុមារអនាថាតាមចិញ្ចើមថ្នល់ ផ្ទះអចិន្ត្រៃយ៍ និងក្រុមគ្រួសាររបស់ពួកគេផ្ទាល់។
- ផ្តល់ការសិក្សាដល់កុមារពិការភ្នែក និងកុមារគ-ថ្លង់ តាមរយៈសាលាពិសេសរបស់អង្គការគ្រួសារថ្មី សហការជាមួយក្រសួងអប់រំយុវជន និងកីឡា។ បើកថ្នាក់អប់រំបញ្ចូលគ្នា និងថ្នាក់សមាហរណកម្ម នៅក្នុងសាលារដ្ឋពាសពេញប្រទេសកម្ពុជាសំរាប់កុមារពិការដែលស្ថិតនៅតំបន់ដាច់ស្រយាល។
- លើកស្ទួយសិល្បៈ វប្បធម៌ខ្មែរ តាមរយៈការអប់រំនៅក្នុងសាលាវប្បធម៌ និងសិល្បៈអង្គការគ្រួសារថ្មី មណ្ឌលគាំពារកុមារអង្គការគ្រួសារថ្មី និងសាលាពិសេសសំរាប់កុមារពិការភ្នែក និងកុមារគ-ថ្លង់គ្រួសារថ្មី។

## ៤. កម្មវិធី ឬសកម្មភាពចំបងៗ:

- សុខមាលភាព
- ការអប់រំ និងជំនួយផ្នែកអប់រំ
- ការជួយអភិវឌ្ឍសិល្បៈ វប្បធម៌

## ៥. តំបន់ការងារ និងប្រភេទកម្មវិធី ឬសកម្មភាពដែលត្រូវអនុវត្ត:

| កម្មវិធី ឬសកម្មភាពការងារ | ផ្នែក | ក្រុមគោលដៅ | តំបន់គោលដៅ | | ប្រភពថវិកា | សហការជាមួយ |
|---|---|---|---|---|---|---|
| | | | ខេត្ត-ក្រុង | ស្រុក-ខ័ណ្ឌ | | |
| ផ្ទះអចិន្ត្រៃយ៍ | សង្គមកិច្ច | កុមារកំព្រា ក្រីក្រជួញដូរ និងកុមារអនាថា | -កំពង់សោម | | - KT France<br>- Fond Maisons | ស.អ.យ |

| | | | | | | |
|---|---|---|---|---|---|---|
| ថ្នាក់សមាហរណកម្មកុមារគ-ថ្លង់ និងកុមារពិការភ្នែកទៅសាលារដ្ឋ | អប់រំ | កុមារគ-ថ្លង់ និងកុមារពិការភ្នែកនៅទូទាំងប្រទេសកម្ពុជា | -កំពង់សោម | | -KT Suisse<br>-Aide et Action | ក្រសួងអប់រំ |

## ៦. បុគ្គលិកបំរើការងារចំនួន៣នាក់ ប្រុសចំនួន២នាក់ ស្រីចំនួន១នាក់

| ល.រ | នាមត្រកូល និងនាមខ្លួន | តួនាទី | លេខទូរស័ព្ទ | ខេត្ត-ក្រុង |
|---|---|---|---|---|
| ១ | សុខ ផាន់ណា | អ្នកសម្របសម្រួលផ្ទះអចិន្ត្រៃយ៍ | ០១២ ៩៩៣ ៨២៣ | ភ្នំពេញ |
| ២ | អេក ស្រេន់ | ប្រធានមណ្ឌល២ | ០១១ ២៦៥ ៩៨៧ | កំពង់សោម |
| ៣ | ឃុន សិទ្ធិស័ក | ប្រធានមណ្ឌល១ | ០១៦ ៣៨៥ ២១៩ | កំពង់សោម |

## ៧. អាស័យដ្ឋានទំនាក់ទំនង:

- ឈ្មោះអ្នកទំនាក់ទំនង: លោក **សុខ ផាន់ណា** តួនាទី **អ្នកសម្របសម្រួលផ្ទះអចិន្ត្រៃយ៍**
- ភូមិ៥ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ
- ភូមិ៤ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហន
- ទូរស័ព្ទអចល័តលេខ: (៨៥៥) ១២ ៩៩៣ ៨២៣,០១១ ២៦៥ ៩៨៧,០១៦ ៣៨៥ ២១៩
- E-mail: krousar-thmey@bigfoot.com
- Website: www.krousar-thmey.org

# អង្គការ ជំនួយផ្នែកច្បាប់ នៃកម្ពុជា
# LEGAL AID OF CAMBODIA (LAC)

## ១. ប្រវត្តិអង្គការ:

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រជាជនកម្ពុជាមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។ អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ដែលមិនគិតកម្រៃ គ្រប់គ្រងដោយក្រុមមេធាវីខ្មែរ ដើម្បីផ្តល់សេវាកម្មផ្លូវច្បាប់ឱ្យប្រជាជនក្រីក្រមានសេរីភាពក្នុងការចោទប្តឹងបាន។ LAC បានបង្កើតឡើងក្នុងខែធ្នូ ឆ្នាំ១៩៩៥ ហើយក៏ជាអង្គការជំនួយផ្នែកច្បាប់លើកដំបូងក្នុងសង្គមកម្ពុជាដែលត្រូវបានទទួលស្គាល់ជាផ្លូវការដោយព្រះរាជានៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និង the Cambodian Bar Association។ LAC ជួយក្នុងការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ដែលត្រូវបានចែងក្នុងគោលការណ៍នៃយុត្តិធម៌ស្មើភាព និងក្បួនច្បាប់ដោយអះអាងឱ្យបាននូវសេវាកម្មផ្នែកច្បាប់ដែលមានគុណភាពខ្ពស់ ដែលត្រូវបានធ្វើជាប្រយោជន៍ដល់អ្នកងាយទទួលរងគ្រោះមួយចំណែកក្នុងសង្គមកម្ពុជា។ ទីស្នាក់ការកណ្តាលរបស់ LAC គឺស្ថិតនៅទីក្រុងភ្នំពេញ និងមានសាខាតាមខេត្តចំនួន៨ ដែលគ្រប់គ្រងដោយក្រុមមេធាវី មាននៅខេត្តបាត់ដំបង សៀមរាប រតនៈគីរី ក្រុងព្រះសីហនុ កោះកុង បន្ទាយមានជ័យ និងកណ្តាល។ នៅទីក្រុងភ្នំពេញ LAC មានផ្នែកមេធាវីទូទៅមួយ និងផ្នែកជំនាញផ្សេងទៀតចំនួន៤ ដូចជា ផ្នែកកុមារ ផ្នែកច្បាប់ដីធ្លី ផ្នែកគំរោងការពារក្តីកុមារ និងផ្នែកច្បាប់ការងារ ដែលទទួលការគាំទ្រដោយ Novid, the Embassy of Finland, International Bridge to Justice(IBJ), Save the Children Norway, the European Union តាមរយៈ DanChurchAid , East West Management Institute (EWMI), the Open Society Institute សំរាប់កម្មវិធីបង្កើនសមត្ថភាពបុគ្គលិក និង ICCO សំរាប់កម្មវិធីទីប្រឹក្សាគ្រប់គ្រង និងអភិវឌ្ឍអង្គការ។

## ២. ទស្សនវិស័យ:

សង្គមកម្ពុជាដែលនីតិរដ្ឋ(សម្មាធិបតេយ្យ) និងសិទ្ធិមនុស្សត្រូវបានគោរព និងអនុវត្ត។

## ៣. បេសកកម្ម:

បេសកម្មរបស់ LAC គឺដើម្បីផ្តល់សេវាកម្មផ្លូវច្បាប់ដែលមានគុណភាព និងតស៊ូមតិដើម្បីជនក្រីក្រកម្ពុជា ដោយពួកគេត្រូវបានគោរពដោយភាពយុត្តិធម៌ និងស្មើភាពគ្នាក្នុងសង្គម។

## ៤. កម្មវិធី ឬសកម្មភាពចំបងៗ:

- កម្មវិធីផ្នែកកុមារ
- គំរោងការពារក្តីកុមារ
- កម្មវិធីច្បាប់ដីធ្លី
- កម្មវិធីច្បាប់ការងារ
- កម្មវិធីច្បាប់ទូទៅ

## ៥. តំបន់ការងារ និងប្រភេទកម្មវិធី ឬសកម្មភាពដែលត្រូវអនុវត្ត:

| កម្មវិធី ឬសកម្មភាពការងារ | ផ្នែក | ក្រុមគោលដៅ | តំបន់គោលដៅ | | ប្រភពថវិកា | សហការជាមួយ |
|---|---|---|---|---|---|---|
| | | | ខេត្ត_ក្រុង | ស្រុក_ខ័ណ្ឌ | | |
| ការធានាសិទ្ធិកុមារក្នុងប្រទេសកម្ពុជា | គំរោងការពារក្ដីកុមារ | កុមារជាជនល្មើស និងកុមារដែលត្រូវគេកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្មកុមារ | - ក្រុងព្រះសីហនុ | - មិត្តភាព<br>- ព្រៃនប់<br>- ស្ទឹងហាវ | European Union through DanChurchAid | សហការគំរោងរវាង LAC LICADHO and DanChurch Aid |
| ការការពារតាមផ្លូវច្បាប់ចំពោះវិវាទដីធ្លី | ផ្នែកច្បាប់ដីធ្លី | ប្រជាជនក្រីក្រដែលដីរបស់ពួកគេត្រូវគេរំលោភ ឬដណ្ដើមយក | - ក្រុងព្រះសីហនុ | - មិត្តភាព<br>- ព្រៃនប់<br>- ស្ទឹងហាវ | East West Management Institute (EWMI) | |
| ការផ្ដល់ការការពារតាមផ្លូវច្បាប់ពីករណីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។ កម្មវិធី Street Law ការតស៊ូមតិដើម្បីកំណែទំរង់ច្បាប់ និងតុលាការ | ផ្នែកមេធាវីទូទៅ | ប្រជាជនក្រីក្រ | - ក្រុងព្រះសីហនុ | - មិត្តភាព<br>- ព្រៃនប់<br>- ស្ទឹងហាវ | Oxfam Netherlands (Novib) and Open Society Institute(OSI) and International Bridge to Justice(IBJ) | |

## ៦. បុគ្គលិកបំរើការងារចំនួន៦១នាក់ ប្រុសចំនួន៤៣នាក់ ស្រីចំនួន១៨នាក់

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | តួនាទី | លេខទូរស័ព្ទ | ខេត្ត_ក្រុង |
|---|---|---|---|---|---|
| ១ | ទេព សុវណ្ណ | ប | ប្រធានសាខាក្រុងព្រះសីហនុ | ០១២ ៤៤១ ៧៩២ | ក្រុងព្រះសីហនុ |
| ២ | ឡុង សាលុច្ប | ប | មេធាវីទទួលបន្ទុកផ្នែកកុមារ | ០១២ ៧០៧ ៧៦០ | ក្រុងព្រះសីហនុ |
| ៣ | ពេជ្រ យ៉ន | ប | អ្នកស៊ើបអង្កេត | ០១២ ៧៦១៧ ៧៦៨ | ក្រុងព្រះសីហនុ |
| ២ | ញឹម ដារីណែត | ស | អ្នកទទួលភ្ញៀវ | ០១២ ៨០៤ ៨១៥ | ក្រុងព្រះសីហនុ |

## ៧. អាសយដ្ឋានទំនាក់ទំនងៈ

- ឈ្មោះអ្នកទំនាក់ទំនងៈ លោក **ឡុង សាលុច្ប** តួនាទី **មេធាវីទទួលបន្ទុកផ្នែកកុមារ**
- ផ្ទះលេខ២៧ មណ្ឌល១ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ
- ទូរស័ព្ទលេខៈ (៨៥៥) ៣៤ ៩៣៣ ៨១៩
  ទូរស័ព្ទចល័តលេខៈ (៨៥៥) ១២ ៧០៧ ៧៦០
- E-mail: lac@online.com.kh
- Web Site: www.lac.org.kh

# អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)

CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN (LICADHO)

## ១. ប្រវត្តិអង្គការ:

បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១មក បណ្ឌិត KEK GALABRU និងជនជាតិកម្ពុជារស់នៅបរទេសផ្សេងទៀត បានរៀបចំបង្កើតឡើងនូវអង្គការលីកាដូ ជាអង្គការក្រៅរដ្ឋាភិបាល និងមិនបំរើនយោបាយ។

នៅខែកក្កដា ឆ្នាំ១៩៩២ អង្គការលីកាដូត្រូវបានទទួលស្គាល់ជាផ្លូវការ ហើយការិយាល័យនៅភ្នំពេញត្រូវបើកភ្លាមៗដើម្បីផ្តល់ការអប់រំដល់អ្នកបោះឆ្នោត និងតាមដានពិនិត្យលើការរំលោភផ្សេងៗពាក់ព័ន្ធនឹងការបោះឆ្នោត ដែលកើតឡើងចំពោះក្រុមគោលដៅនានា។

លីកាដូបានចាប់ផ្តើមបណ្តុះបណ្តាលអំពីការអប់រំដល់អ្នកបោះឆ្នោត សំរាប់ការបោះឆ្នោតដែលរៀបចំឡើងនៅឆ្នាំ១៩៩៣ ហើយបានធ្វើការអង្កេតបរិយាកាសនៃការបោះឆ្នោតជាលើកដំបូងនេះផងដែរ។ ជាបន្តបន្ទាប់ លីកាដូបានផ្តោតជាសំខាន់ លើការរំលោភបំពានសិទ្ធិមនុស្សដែលកើតឡើងនៅក្នុងប្រទេស ជាមួយនឹងសកម្មភាពនេះដែរ លីកាដូក៏ធ្វើសកម្មភាពផ្តោតលើ ការអង្កេតស្តីពីការរំលោភសិទ្ធិ ផ្តល់នូវវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស និងការថែទាំសុខភាពដល់អ្នកទោស និងជនរងគ្រោះ ដោយការរំលោភបំពានសិទ្ធិមនុស្ស។

ឆ្នាំ១៩៩៤ លីកាដូបានពង្រីកគំរោងកម្មវិធីរបស់ខ្លួនបន្ថែមទៀត ដោយបង្កើតឱ្យមានការិយាល័យសិទ្ធិស្ត្រី និងសិទ្ធិកុមារ ហើយមានបុគ្គលិកសរុប១៣០នាក់ទូទាំងខេត្ត-ក្រុង និងស្នាក់ការខេត្ត១២ និងក្រុង១។

លីកាដូបានធ្វើសកម្មភាពជាបន្តបន្ទាប់ៗ ជាពិសេសនៅឆ្នាំ២០០១ លីកាដូបានបង្កើតកម្មវិធីមួយ គឺកម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម ដែលជាកម្មវិធីមួយផ្តោតលើសេវាផ្តល់ការស្តានីតិសម្បទាដល់ជនរងគ្រោះដោយអំពើទារុណកម្មនៅប្រទេសកម្ពុជា។

ឆ្នាំ២០០៥នេះ លីកាដូមានបុគ្គលិកសរុបចំនួន១៤០នាក់ ដែលមានទីស្នាក់ការនៅខេត្តចំនួន១២ និស្នាក់ការភ្នំពេញចំនួន១ ហើយដែលទទួលមូលនិធិពីបណ្តាម្ចាស់អំណោយអន្តរជាតិជាច្រើននៅទូទាំងពិភពលោក។

## ២. ទស្សនវិស័យ:

ដើម្បីសម្រេចបាននូវសង្គមប្រជាធិបតេយ្យមួយ ដែលប្រកបដោយសុខសន្តិភាព និងស្ថេរភាព ហើយដែលរដ្ឋាភិបាល និងស្ថាប័នមានការប្តេជ្ញា និងគោរពសិទ្ធិមនុស្ស និងយុត្តិធមិសង្គម។ គោលដៅ គឺលើកកំពស់គោលការណ៍ស្តីពីសិទ្ធិមនុស្ស និងច្បាប់ដែលមានទិសដៅ កែលម្អឱ្យប្រសើរឡើងនូវការអនុវត្តន៍ច្បាប់ និងការពារប្រជាជនពីការរំលោភបំពានសិទ្ធិមនុស្ស។

## ៣. បេសកកម្ម:

លីកាដូផ្តល់នូវការអប់រំ និងបណ្តុះបណ្តាល ស៊ើបអង្កេតករណីនៃការរំលោភបំពានសិទ្ធិមនុស្ស ផ្តល់នូវជំនួយឧបត្ថម្ភដល់ជនរងគ្រោះ ធ្វើការស្រាវជ្រាវ និងទាក់ទាញមតិគាំទ្រលើបញ្ហាសិទ្ធិសំខាន់ៗ។ លើកកម្ពស់សិទ្ធិមនុស្ស សិទ្ធិកុមារ និងសិទ្ធិស្ត្រី តាមដាន ត្រួតពិនិត្យការរំលោភបំពានសិទ្ធិមនុស្ស និងលក្ខខណ្ឌស្ថានភាពក្នុងពន្ធនាគារ ផ្តល់ការថែទាំផ្នែកវេជ្ជសាស្ត្រដល់អ្នកទោស និងជនរងគ្រោះដោយអំពើរំលោភបំពានសិទ្ធិមនុស្ស និងផ្តល់ឱ្យនូវសេវាកម្មស្តារនីតិសម្បទានចំពោះជនរងគ្រោះដោយការធ្វើទារុណកម្ម។

## ៤. កម្មវិធី ឬសកម្មភាពចំបងៗ:

- ការិយាល័យទាក់ទាញមតិគាំទ្រ ឯកសារ និងធនធានព័ត៌មាន
- ការិយាល័យស៊ើបអង្កេត
- ការិយាល័យប្រឆាំងអំពើទារុណកម្ម
- ការិយាល័យសិទ្ធិស្ត្រី

-ការិយាល័យអប់រំសិទ្ធិមនុស្ស

-ការិយាល័យពេទ្យ

-ការិយាល័យសិទ្ធិកុមារ

មានគំរោងពីរសំខាន់:

-គំរោងDCA ផ្តោតជាពិសេសលើបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍។

-គំរោងODW ផ្តោតលើបបញ្ហាសិទ្ធិកុមារ និងការជួញដូរកុមារ។

## ៥. តំបន់ការងារ និងប្រភេទកម្មវិធី ឬសកម្មភាពដែលត្រូវអនុវត្ត:

| កម្មវិធី ឬសកម្មភាពការងារ | ផ្នែក | ក្រុមគោលដៅ | តំបន់គោលដៅ | | ប្រភពថវិកា | សហការជាមួយ |
|---|---|---|---|---|---|---|
| | | | ខេត្ត-ក្រុង | ស្រុក-ខ័ណ្ឌ | | |
| ការគាំទ្ររៀបចំសហគមន៍ | -ពលកម្មកុមារ<br>-ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ<br>-ទេសចរផ្លូវភេទលើកុមារ<br>-កុមារបំរើតាមផ្ទះ<br>-ការជួញដូរកុមារ | -អាជ្ញាធរមូលដ្ឋាន<br>-រដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល<br>-កុមាររងគ្រោះ និងងាយរងគ្រោះ | -កំពង់សោម | មិត្តភាព<br>មិនទាន់កំនត់ | -ប្រតិបត្តិការមួយថ្ងៃ<br>-សហគមន៍អ៊ឺរ៉ុប<br>-ជំនួយព្រះវិហារដាណឺម៉ាក | -ក្រសួង និងមន្ទីរអប់រំ យុវជននិងកីឡា<br>-មន្ទីរកិច្ចការនារី<br>-មន្ទីរទេសចរណ៍<br>-អង្គការទស្សនៈពិភពលោក<br>-អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា |
| ទេសចរណ៍ផ្លូវភេទ (ពលកម្មកុមារ)<br>-ការជួញដូរកុមារ | សិទ្ធិកុមារ | -កុមារ<br>-អជ្ញាធ័រ<br>-ថៅកែ | -កំពង់សោម | -មិត្តភាព<br>-ស្ទឹងហាវ | - DCA<br>- ODW | |
| ស៊ើបអង្កេតលើសិទ្ធិកុមារ | -ផ្តល់សេវាច្បាប់ បញ្ជូនករណីនិងសេវាសង្គមដល់កុមាររងគ្រោះដោយករណីរំលោភ, អំពើហឹង្សានិងការជួញដូរ។ល។ | កុមាររងគ្រោះ | -កំពង់សោម | គ្រប់តំបន់ | -ប្រតិបត្តិការមួយថ្ងៃ<br>-សហគមន៍អ៊ឺរ៉ុប<br>-ជំនួយព្រះវិហារដាណឺម៉ាក | - Local authorities<br>- Local court<br>- World Vision<br>- Legal Aid<br>- PJJ<br>- CDW<br>- CWCC<br>- MTI |

## ៦. បុគ្គលិកបំរើការងារចំនួន៦នាក់ ប្រុសចំនួន៦នាក់

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | តួនាទី | លេខទូរស័ព្ទ | ខេត្ត-ក្រុង |
|---|---|---|---|---|---|
| ១ | ឃឹម សាខេន | ប | អ្នកសម្របសម្រួល | ០១៦ ៨៩៣ ៧១៦ | កំពង់សោម |
| ២ | ប៊ុល ពន | ប | អ្នកទាក់ទាញមតិគាំទ្រប្រឆាំងពលកម្មកុមារ | ០១៦ ៦៦៦ ៣០៧ | កំពង់សោម |
| ៣ | ជិន មុនី | ប | អ្នកទាក់ទាញមតិគាំទ្រសិទ្ធិកុមារ | ០១២ ១៩៩ ៥៦៥-៨ | កំពង់សោម |
| ៤ | ប៊ួន ណារិទ្ធិ | ប | គ្រូអប់រំសិទ្ធិកុមារ | | កំពង់សោម |
| ៥ | លឹម សុខង៉ា | ប | អ្នកស៊ើបអង្កេត | | កំពង់សោម |
| ៦ | ចាន់ សុជាតិ | ប | អ្នកស្រាវជ្រាវមន្ទីរពន្ធនាគារ | | កំពង់សោម |

## ៧. អាសយដ្ឋានទំនាក់ទំនង:

- ឈ្មោះអ្នកទំនាក់ទំនង: លោក **ឃឹម សាខេន** តួនាទី **អ្នកសម្របសម្រួល**
- ផ្លូវឯករាជ ក្រុមទី៧ មណ្ឌល៣ សង្កាត់ទី២ ខណ្ឌមិត្តភាព កំពង់សោម
- ទូរស័ព្ទអចល័តលេខ (៨៥៥) ៣៤ ៩៣៣ ៧១៦ ទូរស័ព្ទចល័តលេខ: (៨៥៥) ១៦ ៨៩៣ ៦៨៥
- E-mail: contact@licadho.org ,lic.sih@camintel.com
- Website: www.licadho.org

# អង្គការម្លប់តាប៉ាង

M'LOP TAPANG

## ១. ប្រវត្តិអង្គការ:

អង្គការម្លប់តាប៉ាង គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងនូវ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៣មានគោលបំណងសំខាន់គឺ បំរើសេវាកម្មសាធារណៈដោយផ្តល់ឱ្យកុមារតាមថ្នល់នូវអនាគតមួយដែលប្រសើរដែលមិនប្រកាន់ជាតិសាស្រ្ត ពណ៌សំប្បុរ។ សកម្មភាពរបស់អង្គការគឺមិនបង្កើតដើម្បីយកកំរៃឡើយមិនទាក់ទិនទៅនិងសកម្មភាព នយោបាយរបស់គណៈបក្សណាមួយឡើយ និងមិនបំរើឱ្យស្ថាប័ន សាសនា ណាទាំងអស់។

## ២. ទស្សនវិស័យ:

ផ្តល់ឱ្យកុមារតាមថ្នល់នូវអនាគតមួយដែលល្អប្រសើរតាមរយៈ ការអប់រំ ការថែរក្សាសុខភាព ផ្តល់អាហាររូបត្ថម្ភ ការប្រឹក្សាយោបល់ និងការការពារកុមារពីការរំលោភបំពានផ្សេងៗ។

## ៣. បេសកកម្ម:

ខំប្រឹងយ៉ាងខ្លាំងដោយឱ្យកុមារបានចូលរៀន ផ្តល់ឱ្យពួកគេមានឱកាសកសាងខ្លួនធ្វើឱ្យគេមានអំណាចដោយជួយផ្គត់ផ្គង់ផ្នែករាងកាយ ចិត្តសាស្រ្ត ការអប់រំ និង ការបណ្តុះបណ្តាលនូវវិជ្ជាជីវៈ។

## ៣. កម្មវិធី_សកម្មភាពចំបងៗ:

កម្មវិធីជួយកុមារតាមថ្នល់ ដោយផ្តោតទៅលើ កុមាររស់នៅតាមថ្នល់ កុមារនិងគ្រួសាររស់នៅតាមថ្នល់ និងកុមារធ្វើការតាមថ្នល់ក្នុងក្រុងព្រះសីហនុ។

| កម្មវិធី ឬសកម្មភាពការងារ | ផ្នែក | ក្រុមគោលដៅ | តំបន់គោលដៅ | | ប្រភពថវិកា | សហការជាមួយ |
|---|---|---|---|---|---|---|
| | | | ខេត្ត_ក្រុង | ស្រុក_ខ័ណ្ឌ | | |
| ក្នុងមណ្ឌលតាមរយៈមណ្ឌលអប់រំមួយដែលមានសកម្មភាពផ្សេងៗដូចជា:ការផ្តល់នូវអាហាររូបត្ថម្ភ ការអប់រំក្រៅប្រព័ន្ធ ការថែរទាំសុខភាព ការពិគ្រោះយោបល់ អនាម័យនិងការបញ្ជូនទៅតាមសាលារៀនរដ្ឋ ជំនាញវិជ្ជាជីវៈ ការបញ្ជូនពួកគេឱ្យទៅសហគមន៍និងសកម្មភាពផ្សេងៗ | អប់រំ | _កុមាររស់នៅតាមថ្នល់ _កុមារធ្វើការតាមថ្នល់ _គ្រួសារកុមាររស់នៅតាមថ្នល់ | _ក្រុងព្រះសីហនុ និងខេត្តនានាដែលកុមាររស់នៅ | _មិត្តភាព _ស្ទឹងហាវ | ICT SKN AIB Ride Aid | _មន្ទីរអប់រំក្រុងព្រះសីហនុ _មន្ទីរសង្គមកិច្ចក្រុងព្រះសីហនុ _ស្ថាប័នដែលពាក់ព័ន្ធ និងអាជ្ញាធរ |
| មណ្ឌលសំចត មានសកម្មភាពផ្សេងៗដូចជា: ផ្តាច់គ្រឿងញៀនតាមរយៈការធ្វើសកម្មភាពនានា ការថែរទាំសុខភាព ការផ្តល់នូវអាហាររូបត្ថម្ភ ការអប់រំក្រៅប្រព័ន្ធ ការពិគ្រោះយោបល អនាម័យ ការបញ្ជូនទៅតាមសាលារៀនរដ្ឋ ជំនាញវិជ្ជាជីវៈ ការបញ្ជូនពួកគេឱ្យទៅសហគមន៍ | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ក្រៅមណ្ឌល មានសកម្មភាពផ្សេងៗដូចជាៈ ការផ្តល់នូវ អាហាររូបត្ថម្ភ ការថែរទាំសុខភាព ការអប់រំក្រៅប្រព័ន្ធ ការពិគ្រោះយោបល់អនាម័យការបញ្ជូនទៅតាមសាលារៀនរដ្ឋជំនាញវិជ្ជាជីវៈ ការបញ្ជូនពួកគេឱ្យទៅ | ផ្សព្វផ្សាយ និង ផ្តល់អាហារ | - កុមាររស់នៅតាមថ្នល់<br>- កុមារធ្វើការតាមថ្នល់<br>- គ្រួសារកុមាររស់នៅតាមថ្នល់ | - ក្រុងព្រះសីហនុ និងខេត្តនានាដែលកុមាររស់នៅ | - មិត្តភាព<br>- ស្ទឹងហាវ | ICT SKN AIB Ride Aid | - មន្ទីរអប់រំក្រុងព្រះសីហនុ<br>- មន្ទីរសង្គមកិច្ចក្រុងព្រះសីហនុ<br>- ស្ថាប័នដែលពាក់ព័ន្ធ និងអាជ្ញាធរ |

## ៦. បុគ្គលិកបំរើការងារចំនួន១០នាក់ ប្រុសចំនួន៧នាក់ ស្រីចំនួន៣នាក់

| ល.រ | នាមត្រកូល និងនាមខ្លួន | តួនាទី | លេខទូរស័ព្ទ | ខេត្ត-ក្រុង |
|---|---|---|---|---|
| ១ | លោក អ៊ីវ សៅសារិន | នាយក | ០១២ ៥៨៧ ៣៨៤ | ក្រុងព្រះសីហនុ |
| ២ | កញ្ញា ម៉ា គីអ៊ីណូ | អ្នកសំរបសំរួលកម្មវិធី | ០១២ ៥៨៧ ៤០៧ | អង់គ្លេស |
| ៣ | លោក ឆម វុទ្ធី | ជំនួយការរដ្ឋបាល | ០១២ ៨៩៩ ១២៨ | បាត់ដំបង |
| ៤ | កញ្ញា គុយ សុភា | ហិរញ្ញវត្ថុ | ០១២ ២៤៩ ៥៤៨ | ក្រុងព្រះសីហនុ |
| ៥ | លោក ធុច ស៊ីថា | ប្រធានផ្នែកមូលដ្ឋាន | ០១២ ៦៥៧ ៦២៧ | កំពង់ចាម |
| ៦ | លោក ឃុន សាន | ប្រធានផ្នែកអប់រំ | ០១១ ៦១១ ៩៣៥ | កំពត |
| ៧ | កញ្ញា ង៉ូវ ចាន់រ៉ាវី | ប្រធានផ្នែកសុខភាព | ០១១ ៧៦៧ ១៣៣ | កំពត |
| ៨ | លោក ព្រំ ចេត | ប្រធានរដ្ឋបាល | ០១១ ៧៨៥ ៤៥៣ | ក្រុងព្រះសីហនុ |
| ៩ | លោក ម៉េង នឿន | ប្រធានមណ្ឌលស្នាក់នៅ | ០១២ ៦៥៧ ១២៧ | ក្រុងព្រះសីហនុ |
| ១០ | លោក ឈាង ឫទ្ធីយ៉ា | ប្រធានផ្នែកការពារសិទ្ធិកុមារ | ០១២ ៦៤៩ ១២៥ | ក្រុងព្រះសីហនុ |

## ៧. អាសយដ្ឋានទំនាក់ទំនងៈ

- ឈ្មោះអ្នកទំនាក់ទំនងៈ លោក **អ៊ីវ សៅសារិន** តួនាទី **ប្រធានអង្គការ**
- ផ្ទះលេខ១៣១ ផ្លូវ៧មករា មណ្ឌល ០៣ សង្កាត់លេខ ០៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ
- ទូរស័ព្ទលេខៈ (៨៥៥) ៣៤ ៩៣៤ ០៧២ ទូរស័ព្ទចល័តលេខៈ (៨៥៥) ១២ ៥៨៧ ៣៨៤
- ប្រអប់សំបុត្រប៉ុស្តិ៍លេខៈ NA ប្រអប់សំបុត្រស៊ីស៊ីស៊ីលេខៈ NA
- E-mail: info@Mloptapang.org
- Web site: www@Mloptapang.org

# អង្គការស្តាហ្វីសកម្ពុជា
# THE STARFISH CAMBODIA ORGANIZATION

## ១. ប្រវត្តិអង្គការ:

មានជនបរទេសមកពីអង្គការផ្សេងៗ ពីភ្នំពេញមកជួយបុរសពិការម្នាក់ដែលគ្មានអង្គការអាចជួយបាន

## ២. ទស្សនវិស័យ:

ចង់ឱ្យជនក្រីក្រមានអារម្មណ៍ដូចមនុស្សទូទៅដែលអាចមានសិទ្ធិទទួលយកអ្វីគ្រប់យ៉ាងដូចមនុស្សធម្មតា

## ៣. បេសកកម្ម:

ជួយចំពោះជនក្រីក្រគ្រប់ប្រភេទ បង្កើតមុខរបរ សាងសង់ផ្ទះ ជីកអណ្តូងទឹក ជួយផ្នែកសុខភាពចំពោះជនក្រីក្រ

## ៤. កម្មវិធី ឬសកម្មភាពចំបងៗ:

១. បង្កើតមុខរបរ

២. ជួយសាងសង់ផ្ទះ

៣. ផ្តល់សេវាសុខភាព

៤. ជួយស្ត្រីនិងកុមារនៅក្នុងគុក

## ៥. តំបន់ការងារ និងប្រភេទកម្មវិធី ឬសកម្មភាពដែលត្រូវអនុវត្ត:

| កម្មវិធី ឬសកម្មភាពការងារ | ផ្នែក | ក្រុមគោលដៅ | តំបន់គោលដៅ | | ប្រភពថវិកា | សហការជាមួយ |
|---|---|---|---|---|---|---|
| | | | ខេត្ត-ក្រុង | ស្រុក-ខ័ណ្ឌ | | |
| ១. បង្កើតមុខរបរ | ទូទៅ | ប្រជាជនក្រីក្រ | -ក្រុងព្រះសីហនុ | -មិត្តភាព<br>-ព្រៃនប់<br>-ស្ទឹងហាវ | -ហាងកាហ្វេ<br>-សប្បុរជន | -CCBO<br>-CT<br>-KWCD<br>-LICADHO<br>-M'LOP TAPANG |
| ២. ជួយសាងសង់ផ្ទះ | | | | | | |
| ៣. ផ្តល់សេវាសុខភាព | | | | | | |
| ៤. ជួយស្ត្រីនិងកុមារនៅក្នុងគុក | | | | | | |

## ៦. បុគ្គលិកបំរើការងារចំនួន១នាក់ ប្រុសចំនួន១នាក់

| ល.រ | នាមត្រកូល និងនាមខ្លួន | តួនាទី | លេខទូរស័ព្ទ | ខេត្ត-ក្រុង |
|---|---|---|---|---|
| ១ | លោក អ៊ុំ សុខម៉េង | អ្នកសំរបសំរួល | ០១៦ ៧៩០ ៤៦៦ | ក្រុងព្រះសីហនុ |

## ៧. អាសយដ្ឋានទំនាក់ទំនង:

- ឈ្មោះអ្នកទំនាក់ទំនងៈ លោក **អ៊ឹ សុខម៉េង** តួនាទី **អ្នកសំរបសំរួល**
- សង្កាត់លេខ២ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ
- ទូរស័ព្ទលេខៈ (៨៥៥) ១៦ ៧៩០ ៨៦៦
- ប្រអប់សំបុត្រប៉ុស្តិ៍លេខៈ NA ប្រអប់សំបុត្រស៊ីស៊ីស៊ីលេខៈ NA
- E-mail:info@starfishcambodia.org
- Web site: www.STARFISHcambodia.org

# តំបន់ប្រតិបត្តិការការងាររបស់អង្គការនៅក្រុងព្រះសីហនុ

**អង្គការ** **ផ្នែក**

## ១.ក្រុងព្រះស៊ីហនុ

### ខណ្ឌព្រៃនប់

**CCBO**
- ការអប់រំ
- ការផ្សព្វផ្សាយ
- ការបង្កើតបណ្តាញការពារកុមារ
- ការជួយសង្គ្រោះ និងអន្តរាគមន៍
- ឥណទាន និងទុនបង្វិល
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ

**CCPCR**
- អប់រំផ្សព្វផ្សាយ
- កម្មវិធីមណ្ឌលស្ថានីតិសម្បទា

**CNRO**
- ទទួលពាក្យបណ្តឹង
- ស៊ើបអង្កេត អន្តរាគមន៍ និងពិនិត្យឃ្លាំមើលករណីរំលោភសិទ្ធិមនុស្ស
- ចូលរួម និងតស៊ូមតិ ច្បាប់ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ
- ផ្តល់សេវាកម្មផ្នែកច្បាប់ដោយមិនយកកំរៃ
- ផ្សព្វផ្សាយច្បាប់ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ

**Krousar Thmey**
- ផ្ទះអចិន្ត្រៃយ៍
- ថ្នាក់សមាហរណកម្មកុមារគ-ថ្លង់ និងកុមារពិការភ្នែកទៅសាលារដ្ឋ

**LAC**
- គំរោងការពារក្តីកុមារ
- ច្បាប់ដីធ្លី
- ផ្នែកមេធាវីទូទៅ

**LICADHO**
- ផ្តល់សេវាច្បាប់ បញ្ជូនករណីនិងសេវាសង្គមដល់កុមាររងគ្រោះដោយករណីរំលោភ, អំពើហឹង្សា និងការជួញដូរ។ល។

**STRAFISH**
- បង្កើតមុខរបរ
- ជួយសាងសង់ផ្ទះ
- ផ្តល់សេវាសុខភាព
- ជួយស្ត្រីនិងកុមារនៅក្នុងគុក

### ខណ្ឌមិត្តភាព

**CCBO**
- ការអប់រំ
- ការផ្សព្វផ្សាយ
- ការបង្កើតបណ្តាញការពារកុមារ
- ការជួយសង្គ្រោះ និងអន្តរាគមន៍
- ឥណទាន និងទុនបង្វិល
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ

**CCPCR**
- កម្មវិធីមណ្ឌលស្ថានីតិសម្បទា

**CNRO**
- ទទួលពាក្យបណ្តឹង
- ស៊ើបអង្កេត អន្តរាគមន៍ និងពិនិត្យឃ្លាំមើលករណីរំលោភសិទ្ធិមនុស្ស
- ចូលរួម និងតស៊ូមតិ ច្បាប់ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ
- ផ្តល់សេវាកម្មផ្នែកច្បាប់ដោយមិនយកកំរៃ
- ផ្សព្វផ្សាយច្បាប់ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ

**Krousar Thmey**
- ផ្ទះអចិន្ត្រៃយ៍
- ថ្នាក់សមាហរណកម្មកុមារគ-ថ្លង់ និងកុមារពិការភ្នែកទៅសាលារដ្ឋ

**LAC**
- គំរោងការពារក្តីកុមារ
- ច្បាប់ដីធ្លី
- ផ្នែកមេធាវីទូទៅ

**LICADHO**
- ការគាំទ្ររៀបចំសហគមន៍
- ទេសចរណ៍ផ្លូវភេទ(ពលកម្មកុមារ) ការជួញដូរកុមារ
- ផ្តល់សេវាច្បាប់ បញ្ជូនករណីនិងសេវាសង្គមដល់កុមាររងគ្រោះដោយករណីរំលោភ, អំពើហឹង្សា និងការជួញដូរ។ល។

**M'lop Tapang**
- អប់រំ
- ផ្សព្វផ្សាយ និងអប់រំ

**STRAFISH**
- បង្កើតមុខរបរ
- ជួយសាងសង់ផ្ទះ
- ផ្តល់សេវាសុខភាព
- ជួយស្ត្រីនិងកុមារនៅក្នុងគុក

## ខណ្ឌស្ទឹងហាវ

**CCBO**

- ការអប់រំ
- ការផ្សព្វផ្សាយ
- ការបង្កើតបណ្តាញការពារកុមារ
- ការជួយសង្គ្រោះ និងអន្តរាគមន៍
- ឥណទាន និងទុនបង្វិល
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ

**CCPCR**

- កម្មវិធីមណ្ឌលស្តានីតិសម្បទា

**CNRO**

- ទទួលពាក្យបណ្តឹង
- ស៊ើបអង្កេត អន្តរាគមន៍ និងពិនិត្យឃ្លាំមើល ករណីរំលោភសិទ្ធិមនុស្ស
- ចូលរួម និងតស៊ូមតិ ច្បាប់ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ
- ផ្តល់សេវាកម្មផ្នែកច្បាប់ដោយមិនយកកំរៃ
- ផ្សព្វផ្សាយច្បាប់ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ

**Krousar Thmey**

- ផ្ទះអចិន្ត្រៃយ៍
- ថ្នាក់សមាហរណកម្មកុមារគ-ថ្លង់ និងកុមារពិការភ្នែកទៅសាលារដ្ឋ

**LAC**

- គំរោងការពារក្តីកុមារ
- ច្បាប់ដីធ្លី
- ផ្នែកមេធាវីទូទៅ

**LICADHO**

- ទេសចរណ៍ផ្លូវភេទ(ពលកម្មកុមារ) ការជួញដូរកុមារ
- ផ្តល់សេវាច្បាប់ បញ្ជូនករណីនិងសេវាសង្គមដល់កុមាររងគ្រោះដោយករណីរំលោភ, អំពើហឹង្សា និងការជួញដូរ។ល។

**M’lop Tapang**

- អប់រំ
- ផ្សព្វផ្សាយ និងអប់រំ

**STRAFISH**

- បង្កើតមុខរបរ
- ជួយសាងសង់ផ្ទះ
- ផ្តល់សេវាសុខភាព
- ជួយស្ត្រីនិងកុមារនៅក្នុងគុក